**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ ......២២៦.............. សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីចុះត្រួតពិនិត្យលទ្ធផលអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រក្រស៊ីវិលទូទៅឆ្នាំ២០១២ និងឆ្នាំ២០១៣

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងអនុក្រឹត្យលេខ ១៤៥៦ អនក្រ.តត ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការតែងតាំង សមាសភាពគណៈកម្មការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៨២ សជណ.ថក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ស្តីពីគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់ អាវុធ និងគ្រួសារ

- លិខិតលេខ សជណ.ឧស ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការរៀបចំធ្វើការបែងចែកសម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ព្រមទាំងសម្រាប់ប្រជាពលរដ្ឋទូទៅ ដោយអនុលោមទៅតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១២
- សេចក្តីសម្រេចលេខ ០២៧ ជនស.គសសជ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបង្កើតគណៈកម្មការអនុវត្តនីតិវិធីលទ្ធកម្មរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចរចាថ្លៃ និងចុះកិច្ចសន្យាផ្ទាល់ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅចំនួន ១៦ក្នុងការអភិវឌ្ឍន៍ទីតាំងសម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- យោងតាមតម្រូវការចាំបាច់

## **<u>សម្រេច</u>**

**ប្រការ១.**

ត្រូវបានបង្កើតក្រុមការងារ ដើម្បីចុះត្រួតពិនិត្យលទ្ធផលអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅឆ្នាំ២០១២ និងឆ្នាំ២០១៣ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត **ឧុច វនទីតូ** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម និងជាអគ្គលេខាធិការ អ.គ.ស.ស.ជ | ប្រធាន |
| ២- ឯកឧត្តម **ប្រាក់ អង្គារ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **សារេត បូរាមី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៤- ឯកឧត្តម **យី យ៉ាណារ័ត្ន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៥- ឯកឧត្តម **ឈឹម សុគន្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៦- លោក **សយ យោសាកា** | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច និងជាប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ៧- លោក **ស៊ិត បូរ៉េត** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច និងជាសមាជិកPEAC | សមាជិក |
| ៨- លោក **ហាក់ ហ៊ីន** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច និងជាសមាជិកPEAC | សមាជិក |

៩- លោក សែន សង | ប្រធានការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម និងជាមន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | សមាជិក

១០- លោក ប៉ែន បូរ៉ាត់ | អនុប្រធានការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម និងជាមន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | សមាជិក

១១- លោក ហេង សុខសំបូរ | អនុប្រធានការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម និងជាមន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | សមាជិក

១២- លោក ស៊ិន សុខុន | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | សមាជិក

១៣- លោកស្រី នួន មន្ថា | មន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | សមាជិក

១៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក

**ប្រការ២.**

ក្រុមការងារនេះមានភារៈកិច្ចៈ

- ចុះពិនិត្យ និងវាយតម្លៃលទ្ធផលអនុវត្តការងារស្របតាមកិច្ចសន្យា រវាងភាគីម្ចាស់ការ និងភាគីអ្នកទទួលការ ក្នុងការអនុវត្តការងារអភិវឌ្ឍន៍ទីតាំងសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ និងប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ សម្រាប់ឆ្នាំ២០១២ និងឆ្នាំ២០១៣ ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ក្រចេះ បាត់ដំបង កំពត ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ព្រះវិហារ បន្ទាយមានជ័យ កំពង់ធំ រតនគិរី មណ្ឌលគិរី កោះកុង និងខេត្តឧត្តរមានជ័យ
- ធ្វើរបាយការណ៍ លើកយោបល់និងវិធានការដោះស្រាយជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យសម្រេច
- អនុវត្តកិច្ចការផ្សេងៗទៀតដែលឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ប្រគល់ជូន

**ប្រការ៣.**

សមាជិកក្រុមការងារដូចមានចែងក្នុងប្រការ១ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចឲ្យប្រើប្រាស់មន្ត្រីក្រោមឱវាទឲ្យជួយការងារក្នុងករណីចាំបាច់

ប្រការ៤.

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ឯកឧត្តម អស់លោក លោកស្រី ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ..១៥... ខែ ...សីហា... ឆ្នាំ ២០១៣

**ទេសរដ្ឋមន្ត្រី**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលខេត្តគោលដៅ
- មន្ទីរ ដនសស ខេត្តគោលដៅ
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ